# ពិធីការបើកឡើងវិញសម្រាប់ទីកន្លែងបាញ់ទឹកសាធារណៈ

បច្ចុប្បន្នភាពថ្មីៗ៖

6/29/20៖ បានផ្តល់ជូនព័ត៌មានលម្អិតបន្ថែមទាក់ទងនឹងការរាយការណ៍ពីចង្កោមករណីទៅ Public Health

7/8/20៖ បានបន្ថែមព័ត៌មានលម្អិតទាក់ទងនឹងអត្ថប្រយោជន៍នៃការឈប់សម្រាករបស់បុគ្គលិក

7/17/20៖ បានផ្តល់ព័ត៌មានបន្ថែមទាក់ទងនឹងនឹងរបាំងមុខ និងការពិនិត្យរោគសញ្ញាបុគ្គលិក និងភ្ញៀវ

នាយកដ្ឋានសុខភាពសាធារណៈរបស់ខោនធី Los Angeles កំពុងដាក់ចុះនូវវិធីសាស្រ្តតាមដំណាក់កាល ដែលបានគាំទ្រដោយវិទ្យាសាស្ត្រ និងជំនាញការសុខភាពសាធារណៈ ជាមួយផែនទីបង្ហាញផ្លូវរបស់រដ្ឋ California ដើម្បីអនុញ្ញាតឲ្យមានការបើកឡើងវិញយ៉ាងសុវត្ថិភាពនៃទីកន្លែងបាញ់ទឹកសាធារណៈ។

**ទីកន្លែងបាញ់ទឹកដែលស្ថិតនៅក្នុងឧទ្យានកម្សាន្ត គឺត្រូវបិទបន្តដដែលរហូតទាល់តែត្រូវបានអនុញ្ញាតឲ្យបន្តប្រតិបត្តិការដែលបានកែប្រែ ឬប្រតិបត្តិការពេញលេញ។**

ប្រតិបត្តិករទីកន្លែងបាញ់ទឹកសាធារណៈទាំងអស់ដែលត្រូវបានគ្របដណ្តប់ដោយការណែនាំនេះ ត្រូវតែដាក់ចុះនូវវិធានាការណ៍ដែលអាចអនុវត្តបានទាំងអស់ ដែលមានរាយនៅខាងក្រោមបន្ថែមលើផ្នែកដែលទាក់ទងផ្សេងៗនៃពិធីការអាងហែលទឹកសាធារណៈ និងត្រូវត្រៀមខ្លួនដើម្បីពន្យល់ពីមូលហេតុនៃវិធានការណ៍ណាមួយដែលមិនត្រូវបានអនុវត្ត គឺមិនអាចអនុវត្តបាន។

សូមកត់សម្គាល់៖ ឯកសារនេះអាចនឹងត្រូវបានធ្វើបច្ចុប្បន្នភាព នៅពេលដែលមានព័ត៌មាន និងធនធានបន្ថែម ដូច្នេះសូមប្រាកដថាពិនិត្យមើលគេហទំព័រ LA County http://www.ph.lacounty.gov/media/Coronavirus/ ជាប្រចាំសម្រាប់បច្ចុប្បន្នភាពផ្សេងៗទៅលើឯកសារនេះ។

បញ្ជីត្រួតពិនិត្យនេះគ្របដណ្តប់៖

(1) គោលការណ៍កន្លែងធ្វើការ និងការអនុវត្តដើម្បីការពារសុខភាពបុគ្គលិក
(2) វិធានការណ៍ដើម្បីធានាបាននូវការរក្សាគំលាតរាងកាយ
(3) វិធានការណ៍ដើម្បីធានាបាននូវការគ្រប់គ្រងការឆ្លងជំងឺ
(4) ការទំនាក់ទំនងជាមួយបុគ្គលិក និងសាធារណជន
(5) វិធានការណ៍ដែលធានាបាននូវការប្រើប្រាស់សេវាកម្មសំខាន់ៗដោយស្មើភាព

ចំណុចសំខាន់ៗទាំងប្រាំនេះ ត្រូវតែបានដោះស្រាយ ស្របពេលដែលទីកន្លែងរបស់អ្នកបង្កើតពិធីការបើកឡើងវិញណាមួយ។

**អាជីវកម្មទាំងអស់ដែលត្រូវបានគ្របដណ្តប់ដោយការណែនាំនេះ ត្រូវតែដាក់ចុះនូវវិធានការណ៍ដែលអាចអនុវត្តបានទាំងអស់ ដែលមានរាយនៅខាងក្រោម និងត្រូវត្រៀមខ្លួនដើម្បីពន្យល់ពីមូលហេតុនៃវិធានការណ៍ណាមួយដែលមិនត្រូវបានអនុវត្ត គឺមិនអាចអនុវត្តបានសម្រាប់អាជីវកម្ម។**

**ឈ្មោះអាជីវកម្ម៖** ______________________

**អាសយដ្ឋានទីកន្លែង៖** ______________________

**កាលបរិច្ឆេទចុះផ្សាយ៖** ______________________

## A. គោលការណ៍ និងការអនុវត្តនៅកន្លែងធ្វើការដើម្បីការពារសុខភាពបុគ្គលិក (គូសធីកទាំងអស់ដែលអនុវត្តសម្រាប់ទីកន្លែង)

- ☐ មនុស្សគ្រប់គ្នាដែលអាចបំពេញកិច្ចការរបស់ខ្លួនពីផ្ទះ ត្រូវបានណែនាំឲ្យធ្វើដូច្នោះ។
- ☐ បុគ្គលិកងាយរងគ្រោះ (អ្នកដែលមានអាយុលើ 65 ឆ្នាំ អ្នកដែលមានបញ្ហាសុខភាពរ៉ាំរ៉ៃ) ត្រូវបានកំណត់ឲ្យធ្វើការងារដែលអាចធ្វើបានពីផ្ទះនៅគ្រប់ពេលដែលអាចធ្វើទៅបាន។
- ☐ បុគ្គលិកទាំងអស់ត្រូវបានប្រាប់ថាមិនឲ្យមកធ្វើការ បើសិនជាឈឺ និងត្រូវអនុវត្តតាមការណែនាំរបស់ DPH សម្រាប់ការដាក់ខ្លួនឯងឲ្យនៅដាច់ដោយឡែក បើសិនជាអាចធ្វើបាន។
    - ○ បង្កើតបញ្ជីឈ្មោះក្រុមបុគ្គលិកបម្រុងដែលបានទទួលការបណ្តុះបណ្តាល។
    - ○ បុគ្គលិកបានទទួលព័ត៌មានអំពីអត្ថប្រយោជន៍នៃការឈប់សម្រាកដែលឧបត្ថម្ភដោយនិយោជក ឬរដ្ឋាភិបាលដែលបុគ្គលិកអាចនឹងមានសិទ្ធិទទួល ដែលនឹងធ្វើឲ្យវាកាន់តែមានភាពងាយស្រួលផ្នែកហិរញ្ញវត្ថុក្នុងការស្ថិតនៅផ្ទះ។ មើលព័ត៌មានបន្ថែមស្តីពី កម្មវិធីរដ្ឋាភិបាលដែលគាំទ្រការឈប់សម្រាកឈឺ និងសំណងបុគ្គលិកសម្រាប់ជំងឺ COVID-19 ដោយរាប់បញ្ចូលទាំងសិទ្ធិឈប់សម្រាកឈឺរបស់បុគ្គលិកក្រោម ច្បាប់ស្តីពីការឆ្លើយតបនឹងមេរោគកូរ៉ូណាដោយយកគ្រួសារជាអាទិភាព (Families First Coronavirus Response Act) និងសិទ្ធិរបស់បុគ្គលិកដើម្បីទទួលអត្ថប្រយោជន៍សំណងបុគ្គលិក និងការសន្និដ្ឋាននៃភាពទាក់ទងនឹងការងាររបស់ជំងឺ COVID-19 ពាក់ព័ន្ធនឹងបទបញ្ជាប្រតិបត្តិលេខ N-62-20 របស់អភិបាលរដ្ឋ។
- ☐ បន្ទាប់ពីទទួលព័ត៌មានថាមានបុគ្គលិកម្នាក់ ឬច្រើននាក់ធ្វើតេស្តវិជ្ជមាន ឬមានរោគសញ្ញាដែលដូចគ្នាជាមួយជំងឺ COVID-19 (ករណី) និយោជកមានគម្រោង ឬពិធីការដើម្បីឲ្យករណីទាំងនោះដាក់ខ្លួនឲ្យនៅដាច់ដោយឡែកនៅផ្ទះ និងតម្រូវឲ្យមានការនៅដាច់ពីគេដោយខ្លួនឯងភ្លាមៗសម្រាប់បុគ្គលិកដែលមានការប៉ះពាល់ជាមួយករណីនៅកន្លែងធ្វើការ។ គម្រោងរបស់និយោជកគួរតែពិចារណាពីពិធីការសម្រាប់បុគ្គលិកដែលបាននៅដាច់ពីគេទាំងអស់ ដើម្បីអាចទទួលបាន ឬធ្វើតេស្តរកជំងឺ COVID-19 ដើម្បីកំណត់ថាតើមានការប៉ះពាល់នៅកន្លែងធ្វើការបន្ថែមទៀតឬក៏អត់ ដែលអាចតម្រូវឲ្យមានវិធានការណ៍គ្រប់គ្រងជំងឺ COVID-19 បន្ថែម។ មើលការណែនាំសុខភាពសាធារណៈនៅលើ ការឆ្លើយតបនឹងជំងឺ COVID-19 នៅកន្លែងធ្វើការ។
- ☐ នៅក្នុងករណីដែលម្ចាស់អាជីវកម្ម អ្នកគ្រប់គ្រង ឬប្រតិបត្តិករដឹងថាមានករណីជំងឺ COVID-19 ចំនួនបី (3) ឬច្រើនជាងនេះនៅកន្លែងធ្វើការក្នុងរយៈពេល 14 ថ្ងៃ នោះនិយោជកត្រូវតែរាយការណ៍ពីចង្កោមនេះទៅនាយកដ្ឋានសុខភាពសាធារណៈតាមរយៈលេខ (888) 397-3993 ឬ (213) 240-7821។ បើសិនជាការឆ្លងជាចង្កោមត្រូវបានរកឃើញនៅកន្លែងការងារ នាយកដ្ឋានសុខភាពសាធារណៈនឹងចាប់ផ្តើមការឆ្លើយតបនឹងការឆ្លងជាចង្កោមដែលរួមមានការផ្តល់ការណែនាំ និងអនុសាសន៍អំពីការគ្រប់គ្រងការឆ្លងជំងឺ ការគាំទ្របច្ចេកទេស និងវិធានការណ៍គ្រប់គ្រងដែលជាក់លាក់តាមតំបន់។ អ្នកគ្រប់គ្រងករណីសុខភាពសាធារណៈនឹងត្រូវបានចាត់តាំងសម្រាប់ធ្វើការស៊ើបអង្កេតលើចង្កោមនេះ ដើម្បីជួយដឹកនាំការឆ្លើយតបនៅទីកន្លែង។
- ☐ ការត្រួតពិនិត្យបុគ្គលិក ត្រូវបានធ្វើឡើងមុនពេលបុគ្គលិកអាចនឹងចូលមកកាន់កន្លែងធ្វើការ។ ការត្រួតពិនិត្យត្រូវតែរាប់បញ្ចូលការពិនិត្យទាក់ទងនឹងការក្អក ការដកដង្ហើមខ្លី ការពិបាកដកដង្ហើម និងអការគ្រុនក្តៅឬគ្រុនរងា និងថាតើបុគ្គលិកបានប៉ះពាល់ជាមួយបុគ្គលដែលត្រូវបានគេដឹងថាបានឆ្លងជំងឺ COVID-19 ក្នុងរយៈពេល 14 ថ្ងៃចុងក្រោយឬក៏អត់។ ការត្រួតពិនិត្យទាំងនេះអាចធ្វើបានពីចម្ងាយ ឬដោយផ្ទាល់នៅពេលបុគ្គលិកមកដល់។ ការពិនិត្យសីតុណ្ហភាពក៏គួរតែធ្វើឡើងនៅកន្លែងធ្វើការផងដែរ បើសិនជាអាចធ្វើបាន។
- ☐ បុគ្គលិកដែលមានការប៉ះពាល់ជាមួយអ្នកដទៃទទួលបានរបាំងមុខសមស្របដែលគ្របច្រមុះ និងមាត់ដោយឥតគិតថ្លៃ។ បុគ្គលិកត្រូវពាក់របាំងមុខនេះគ្រប់ពេលវេលាក្នុងអំឡុងថ្ងៃធ្វើការ នៅពេលប៉ះពាល់ ឬទំនងជាប៉ះពាល់ជាមួយអ្នកដទៃ។ បុគ្គលិកដែលត្រូវបានណែនាំដោយអ្នកផ្តល់សេវាវេជ្ជសាស្ត្ររបស់ខ្លួនថាពួកគេមិនគួរពាក់របាំងមុខ គួរពាក់សន្ទះបាំងមុខដែលមានក្រណាត់រុំពីគែមខាងក្រោម ដើម្បីអនុលោមតាមបទបញ្ជារបស់រដ្ឋដរាបណាស្ថានភាពសុខភាពរបស់ពួកគេអនុញ្ញាតឲ្យធ្វើដូច្នេះ។ ក្រណាត់រុំដែលមានទម្រង់រឹតតឹងខាងក្រោមចង្កាគឺជាការល្អ។ មិនគួរប្រើម៉ាស់ដែលមានវ៉ាល់មួយផ្លូវឡើយ។ បុគ្គលិកមិនចាំបាច់ពាក់ក្រណាត់បាំងមុខពេលនៅម្នាក់ឯងនៅក្នុងការិយាល័យឯកជន ឬបន្ទប់តូចដែលមានរបាំងរឹងការពារខ្ពស់ជាងកម្ពស់បុគ្គលិកនៅពេលឈរនោះទេ។
- ☐ បុគ្គលិកត្រូវបានណែនាំឲ្យបោកគក់របាំងមុខរបស់ខ្លួនជារៀងរាល់ថ្ងៃ។
- ☐ បុគ្គលិកមិនចាំបាច់ពាក់ក្រណាត់បាំងមុខពេលនៅក្នុងទឹកនោះទេ។
- ☐ ការសម្រាកត្រូវបានកំណត់ដាច់ៗពីគ្នាដើម្បីប្រាកដថាបុគ្គលិកអាចរក្សាគំលាតប្រាំមួយ (6) ហ្វីតពីគ្នានៅក្នុងបន្ទប់សម្រាកនៅគ្រប់ពេលវេលា។

☐ បុគ្គលិកត្រូវបានហាមឃាត់មិនឲ្យបរិភោគ ឬផឹកនៅកន្លែងណាមួយក្រៅពីតំបន់ដែលបានកំណត់ឡើយ ដើម្បីធានាថាម៉ាស់ត្រូវបានពាក់គ្រប់ពេលវេលា និងត្រឹមត្រូវ។

☐ សារធាតុសម្លាប់មេរោគ និងការផ្គត់ផ្គង់ដែលពាក់ព័ន្ធគឺមានសម្រាប់បុគ្គលិកនៅតាមទីតាំងដូចខាងក្រោមនៃទីកន្លែង៖

__________________________________________________

☐ ទឹកអនាម័យលាងដៃដែលមានប្រសិទ្ធភាពប្រឆាំងជំងឺ COVID-19 គឺមានសម្រាប់បុគ្គលិកទាំងអស់នៅតាមទីតាំងដូចខាងក្រោមនៃទីកន្លែង៖

__________________________________________________

☐ បុគ្គលិកត្រូវបានអនុញ្ញាតឲ្យសម្រាកឲ្យបានញឹកញាប់ដើម្បីលាងដៃរបស់ខ្លួន។

☐ ច្បាប់ចម្លងនៃពិធីការនេះត្រូវបានចែកចាយទៅបុគ្គលិកនីមួយៗ។

☐ ស្រេចចិត្ត – ពិពណ៌នាពីវិធានការណ៍ផ្សេងទៀត៖

__________________________________________________

## B. វិធានការណ៍ដើម្បីធានាបាននូវការរក្សាគំលាតសង្គម

☐ ដាក់កម្រិតការប្រើប្រាស់ទីកន្លែងបាញ់ទឹក ដើម្បីធានាថាអ្នកប្រើអាចរក្សាគម្លាតរាងកាយ 6 ហ្វីតពីមនុស្សដែលមិនមែនជាសមាជិកគ្រួសាររបស់ខ្លួនឲ្យបានច្រើនបំផុតតាមដែលអាចធ្វើបាន។ ការប្រើប្រាស់អត្រាភ្ញៀវ 1 នាក់ក្នុងទីកន្លែងបាញ់ទឹក 36 ហ្វីតការ៉េអាចជួយសម្រេចដែនកំណត់នេះបាន។

- ចង្អុលបង្ហាញពីទំហំហ្វីតការ៉េនៃទីកន្លែងបាញ់ទឹកបច្ចុប្បន្ន៖ ________ ចង្អុលបង្ហាញពីចំនួនភ្ញៀវដែលបានអនុញ្ញាតដោយប្រើអត្រាភ្ញៀវ 1 នាក់ក្នុង 36 ហ្វីតការ៉េ៖ __________
- ពិចារណាអនុវត្តការកក់ទុកជាមុនសម្រាប់ការប្រើប្រាស់ទីកន្លែងបាញ់ទឹក។

☐ ចាត់តាំងមនុស្សដែលទទួលខុសត្រូវលើការត្រួតពិនិត្យ និងធ្វើឲ្យប្រាកដថាចំនួនអតិបរមានៃអ្នកប្រើទីកន្លែងបាញ់ទឹកមិនលើសពីចំនួនដែលបានកំណត់ខាងលើ។ បុគ្គលដែលបានចាត់តាំង ក៏ទទួលខុសត្រូវលើការធ្វើឲ្យប្រាកដថាពិធីការទាំងនេះត្រូវបានគោរពតាមជារៀងរាល់ថ្ងៃផងដែរ។ ស្លាកសញ្ញាក៏គួរណែនាំឲ្យឪពុកម្តាយជួយធ្វើឲ្យប្រាកដថាកុមារអនុវត្តតាមការរក្សាគំលាតរាងកាយ និងប្រើប្រាស់ក្រណាត់បាំងមុខសម្រាប់កុមារដែលមានអាយុចាប់ពី 3 ឆ្នាំឡើងទៅ នៅពេលដែលពួកគេមិននៅក្នុងទឹកផងដែរ។

☐ រៀបចំជួរដោយមានការសម្គាល់ ឬវិធីផ្សេងទៀតដើម្បីជួយធានាបាននូវការរក្សាគំលាតរាងកាយ ខណៈពេលរង់ចាំចូលទៅកាន់កន្លែងបាញ់ទឹក (Splash Pad)។

☐ បង្កើតម៉ោងធ្វើប្រតិបត្តិការនៃកន្លែងបាញ់ទឹក ដើម្បីអនុញ្ញាតឲ្យមានការត្រួតពិនិត្យបានសមស្រប។

☐ របាំងគួរត្រូវបានប្រើដើម្បីហ៊ុមព័ទ្ធទីកន្លែងបាញ់ទឹក ដើម្បីគ្រប់គ្រងការចេញចូល។

☐ ទីកន្លែងអង្គុយនៅក្នុងទីកន្លែងបាញ់ទឹក គួរត្រូវបានយកចេញ ឬហាមប៉ះពាល់ដើម្បីហាមឃាត់ការប្រមូលផ្តុំ។

☐ វិធានការណ៍ដើម្បីធានាបាននូវការរក្សាគំលាតសង្គម (បុគ្គលស្ថិតនៅគំលាតយ៉ាងតិច 6 ហ្វីតពីមនុស្សដែលពួកគេមិនរស់នៅជាមួយ) ត្រូវបានអនុវត្ត។

☐ បន្ទប់ផ្លាស់ប្តូរសំលៀកបំពាក់ និងបន្ទប់ទឹកត្រូវបានត្រួតពិនិត្យដើម្បីធ្វើឲ្យប្រាកដថាចំនួនមនុស្សនៅខាងក្នុងនៅពេលតែមួយ អនុញ្ញាតឲ្យមានការរក្សាគំលាតរាងកាយសមស្រប។

☐ ហាមឃាត់ការជប់លៀង ឬការប្រមូលផ្តុំក្រៅពីក្រុមគ្រួសារតែមួយនៅក្នុងទីកន្លែងទូទៅទាំងអស់រាប់បញ្ចូលទាំងទីកន្លែងបាញ់ទឹកផងដែរ។

## C. វិធានការណ៍ដើម្បីគ្រប់គ្រងការឆ្លងជំងឺ

☐ ប្រឹក្សាជាមួយក្រុមហ៊ុន ឬវិស្វករដែលបានរៀបចំទីកន្លែងលេងទឹកដើម្បីសម្រេចថាតើបញ្ជីសារធាតុសម្លាប់មេរោគ N មួយណាដែលត្រូវបានអនុម័តដោយ EPA គឺល្អបំផុតសម្រាប់ទីកន្លែងមានទឹកនេះ។

- ☐ កម្រិតក្លរីនគួរត្រូវបានធ្វើតេស្តជារៀងរាល់ម៉ោង ហើយកម្រិត PH គួរត្រូវបានធ្វើតេស្តពីរដងក្នុងមួយថ្ងៃ ឬញឹកញាប់ជាងនេះតាមការចាំបាច់។ សមាសធាតុគីមីទឹកគួរលើសពីការណែនាំអប្បបរមា។
- ☐ សម្រាប់ទីកន្លែងដែលមិនបានធ្វើប្រតិបត្តិការ ចូរបង្ហូរទឹកក្តៅនិងទឹកត្រជាក់លាយគ្នារយៈពេលប្រាំនាទីមុននឹងបើកឡើងវិញ ដើម្បីប្តូរទឹកនៅក្នុងបំពង់ទឹកជាមួយនឹងការផ្គត់ផ្គង់ទឹកសាប និងមានសុវត្ថិភាព។
- ☐ អនុវត្តផែនការសម្អាត និងសម្លាប់មេរោគសម្រាប់ផ្ទៃដែលបានប៉ះពាល់ជាញឹកញាប់ និងសម្រាប់វត្ថុដែលប្រើរួមគ្នារៀងរាល់ពេលដែលពួកវាត្រូវបានប្រើ។ ប្រើប្រាស់សារធាតុសម្លាប់មេរោគដែលបានអនុម័តដោយ EPA។ វត្ថុខាងក្រោមនេះនឹងត្រូវបានសម្អាត និងសម្លាប់មេរោគជាញឹកញាប់ តាមកាលវិភាគដូចខាងក្រោម៖
  - ដៃទ្វារ និងផ្ទៃនៃបន្ទប់ទឹក ទីកន្លែងលាងដៃ ទីកន្លែងប្តូរខោទឹកនោម និងកន្លែងងូតទឹក ________________________________
  - ទីកន្លែងប្រើប្រាស់ទូទៅ (ឧ. ទូចាក់សោ) ________________________________
  - បន្ទប់ទឹក និងបន្ទប់ងូតទឹក________________________________
  - ផ្សេងទៀត ________________________________
- ☐ បិទទីកន្លែងតាមការចាំបាច់ដើម្បីធ្វើការសម្អាត និងសម្លាប់មេរោគ។
  - យកសម្រាម និងកម្ទេចកម្ទីចេញ ផ្លុំ ឬជូតសម្អាតទីកន្លែង។ ត្រួតពិនិត្យ និងរាយការណ៍ពីគ្រោះថ្នាក់ជាសក្តានុពលណាមួយ។
  - ធ្វើឲ្យប្រាកដថាប្រព័ន្ធបង្ហូរទឹកចេញទាំងអស់មិនមានកម្ទេចកម្ទី ថ្ម កែវ ឬវត្ថុប្លែកផ្សេងៗទៀត។
- ☐ ភ្ញៀវដែលមកដល់ទីកន្លែងត្រូវបានរំលឹកឲ្យពាក់របាំងមុខនៅគ្រប់ពេលវេលា (លើកលែងតែពេលបរិភោគ ឬផឹក បើសិនជាអាចធ្វើបាន) ខណៈពេលនៅក្នុងទីកន្លែង ឬនៅលើទីធ្លានៃទីកន្លែង។ នេះអនុវត្តទៅលើមនុស្សធំទាំងអស់ និងកុមារដែលមានអាយុចាប់ពី 2 ឆ្នាំឡើងទៅ។ មានតែបុគ្គលដែលត្រូវបានណែនាំមិនឲ្យពាក់របាំងមុខដោយអ្នកផ្តល់សេវាវេជ្ជសាស្ត្រប៉ុណ្ណោះទើបត្រូវបានលើកលែងពីការពាក់នេះ។ ដើម្បីគាំទ្រសុវត្ថិភាពបុគ្គលិករបស់អ្នក និងភ្ញៀវផ្សេងទៀត គួរផ្តល់របាំងមុខឲ្យភ្ញៀវដែលមកដល់ដោយគ្មានវា។
- ☐ ក្រណាត់បាំងមុខមិនត្រូវបានតម្រូវខណៈពេលនៅក្នុងទឹកនោះទេ។
- ☐ ការត្រួតពិនិត្យរោគសញ្ញាត្រូវបានធ្វើឡើងមុនពេលភ្ញៀវអាចនឹងចូលក្នុងទីកន្លែងបាញ់ទឹក។ ការត្រួតពិនិត្យ ត្រូវតែរាប់បញ្ចូលការពិនិត្យទាក់ទងនឹងការក្អក ការដកដង្ហើមខ្លី ការពិបាកដកដង្ហើម និងអការគ្រុនក្តៅឬគ្រុនរងា។ ការត្រួតពិនិត្យទាំងនេះអាចធ្វើបានដោយផ្ទាល់ ឬតាមរយៈវិធីផ្សេងដូចជាការពិនិត្យរោគសញ្ញាតាមអនឡាញ ឬតាមរយៈស្លាកសញ្ញាដែលបានបិទនៅច្រកចូលទីកន្លែងដោយថ្លែងថាភ្ញៀវដែលមានរោគសញ្ញាទាំងនេះមិនគួរចូលក្នុងទីកន្លែងឡើយ។
- ☐ ធ្វើឲ្យប្រាកដថាមានផ្តល់ការផ្គត់ផ្គង់គ្រប់គ្រាន់ដើម្បីគាំទ្រអនាម័យដែលមានសុខភាពល្អ នៅគ្រប់ពេលវេលាទាំងអស់។ ការផ្គត់ផ្គង់រួមមានសាប៊ូ ទឹកអនាម័យលាងដៃដែលមានជាតិអាល់កុលយ៉ាងតិច 60% ក្រដាសជូត ក្រដាសជូតមាត់ និងធុងសម្រាម
- ☐ ទឹកបាញ់សម្រាប់ផឹកត្រូវបានគ្របដើម្បីទប់ស្កាត់ការប្រើប្រាស់។
- ☐ បុគ្គលម្នាក់ៗគួរយកម្ហូបអាហារ និងភេសជ្ជៈរបស់ខ្លួន ដែលមិនគួរចែករំលែកជាមួយមនុស្សក្រៅគ្រួសារឡើយ
- ☐ លក្ខណៈពិសេសដែលមានការប៉ះពាល់ច្រើនដែលអាចត្រូវបានប្រើដោយកុមារ ដូចជាកាណុងដៃ គួរត្រូវបានបិទ គ្រប ឬដោះចេញ។
- ☐ មិនអនុញ្ញាតឲ្យមានរបស់លេងទឹកផ្ទាល់ខ្លួននៅពេលណាមួយ ឬនៅជុំវិញទីកន្លែងបាញ់ទឹកឡើយ។
- ☐ វត្ថុដែលយកមកកាន់ទីកន្លែងបាញ់ទឹក មិនគួរចែករំលែកជាមួយអ្នកដទៃក្រៅគ្រួសារឡើយ
- ☐ បុគ្គលត្រូវបានលើកទឹកចិត្តឲ្យយកកន្សែងរបស់ខ្លួនមកកាន់ទីកន្លែងបាញ់ទឹក និងមិនគួរប្រើកន្សែងរួមគ្នាជាមួយមនុស្សនៅក្រៅគ្រួសាររបស់ខ្លួនឡើយ។

## D. វិធានការណ៍ដែលទំនាក់ទំនងជាមួយសាធារណជន

- ☐ ច្បាប់ចម្លងនៃពិធីការនេះត្រូវបានបិទផ្សាយនៅគ្រប់ច្រកចូលសាធារណៈទាំងអស់មកកាន់ទីកន្លែងបាញ់ទឹក។
- ☐ ស្លាកសញ្ញាត្រូវបានបិទផ្សាយនៅច្រកចូលសាធារណៈនីមួយៗនៃទីកន្លែងបាញ់ទឹក ដើម្បីជម្រាបជូនអ្នកប្រើឲ្យ៖
  - ស្ថិតនៅផ្ទះបើសិនជាពួកគេឈឺ ឬមានរោគសញ្ញាដូចគ្នានឹងជំងឺ COVID-19។
  - រក្សាគំលាតសង្គមប្រាំមួយហ្វីតពីមនុស្សដែលមិនមែនជាសមាជិកគ្រួសារទៅតាមកម្រិតដែលអាចធ្វើបាន និងកុំមានការប៉ះពាល់រាងកាយដែលមិនចាំបាច់ផ្សេងៗ នៅក្នុងទីកន្លែងបាញ់ទឹក។ ឪពុកម្តាយគួរជួយកូនរបស់ខ្លួនអនុវត្តតាមការណែនាំទាំងនេះ។
  - លាងដៃឲ្យបានញឹកញាប់ ឬប្រើទឹកអនាម័យលាងដៃនៅពេលចូលមកក្នុងទីកន្លែងបាញ់ទឹក
  - ពាក់របាំងមុខ នៅពេលធ្វើដំណើរកាត់ទីកន្លែងទូទៅនៃទីកន្លែង ដោយរាប់បញ្ចូលទាំងទៅ និងមកពីទីកន្លែងបាញ់ទឹក និងនៅក្នុងបន្ទប់ទឹករួម។ រំលឹកកុមារឲ្យដោះក្រណាត់បាំងមុខចេញ នៅពេលចូលក្នុងឧបករណ៍បាញ់ទឹក។

## E. វិធានការណ៍ដែលធានាបាននូវការប្រើប្រាស់សេវាកម្មសំខាន់ៗដោយស្មើភាព

- ☐ សេវាកម្មដែលចាំបាច់ខ្លាំងសម្រាប់ភ្ញៀវ/អ្នកតាំងទីលំនៅ ត្រូវបានផ្តល់អាទិភាព។
- ☐ វិធានការណ៍ត្រូវបានអនុវត្តដើម្បីធានាបាននូវការទទួលបានទំនិញ និងសេវាកម្មសម្រាប់អ្នកដែលមានការលំបាកក្នុងការផ្លាស់ទី និង/ឬដែលមានហានិភ័យ(risk)ខ្ពស់នៅទីសាធារណៈ។

អ្នកក៏អាចរកមើលការណែនាំពី Centers for Disease Control and Prevention សម្រាប់ការរក្សាគំលាតសង្គម និងដំណើរការសម្លាប់មេរោគនៅអគារ/ផ្ទៃដែលមាននៅ https://www.cdc.gov/coronavirus/2019-ncov/php/water.html ផងដែរ។